International Labour Organization



**ការកសាងភាពធន់ក្នុងអំឡុងពេល និងក្រោយការរាតត្បាតនៃជំងឺកូវីដ-១៩**

គោលការណ៍ណែនាំអំពីកូវីដ-១៩ និងបញ្ជីសកម្មភាព

សម្រាប់រោងចក្រកាត់ដេរ និងអ្នកគ្រប់គ្រង

# ការស្វែងរកប្រភពចំណូលផ្សេងទៀត

គោលការណ៍ណែនាំនេះជួយអ្នកគ្រប់គ្រងរោងចក្រក្នុងការកំណត់ប្រភពចំណូលថ្មីៗ ដើម្បីធានាថារោងចក្រអាចឆ្លងកាត់វិបត្តិនៃការរីករាតត្បាតនៃជំងឺកូវីដ-១៩ និងបង្កើតភាពធន់របស់ខ្លួន។

## ការចាប់ផ្តើម

រួមបញ្ចូលៈ បញ្ជីសកម្មភាព

**គោលការណ៍ណែនាំនេះផ្តោតលើៈ**

- ហេតុអ្វីបានជាយើងគួរកំណត់ប្រភពចំណូលផ្សេងទៀតក្នុងអំឡុងពេលវិបត្តិនៃជំងឺរាតត្បាតនេះ
- វិធីកំណត់ប្រភពប្រាក់ចំណូលដែលសមស្របសម្រាប់រោងចក្ររបស់អ្នក
- អនុសាសន៍ស្តីពីវិធីស្វែងរកប្រភពចំណូលផ្សេងទៀតក្នុងអំឡុងពេលនៃជំងឺកូវីដ-១៩ ក៏ដូចជានៅពេលក្រោយទៀត

## 1. ហេតុអ្វីបានជាប្រភពចំណូលថ្មីៗមានសារៈសំខាន់ក្នុងអំឡុងពេល និងក្រោយការរាតត្បាតនៃមេរោគកូវីដ-១៩

បច្ចុប្បន្ន រោងចក្រកាត់ដេរកំពុងរងការខាតបង់ប្រាក់ចំណូល ដោយសារអតិថិជនជាច្រើនបានលុបចោល ឬបញ្ឈប់ការបញ្ជាទិញ កាត់បន្ថយបរិមាណបញ្ជាទិញ និង/ឬពន្យារយៈពេលនៃការការបង់

ប្រាក់។ សម្រាប់រោងចក្រដែលបានបញ្ចប់ការបញ្ជាទិញ ឬកំពុងដំណើរការងារ (WIP) ដែលតម្រូវឱ្យពួកគេទូទាត់វិក័យប័ត្រសម្រាប់វត្ថុធាតុដើមដែលបានបញ្ជាទិញ ដូចជាក្រណាត់ គ្រឿងតុបតែង ឬការវេចខ្ចប់ ស្ថានភាពនេះធ្វើឱ្យពួកគេជួបការលំបាកផ្នែកហិរញ្ញវត្ថុ។

**ការធ្វើពិពិធកម្មប្រភពចំណូលនៃរោងចក្ររបស់អ្នកអាចធ្វើឱ្យរោងចក្ររបស់អ្នកកាន់តែមានភាពធន់នឹងវិបត្តិនាពេលអនាគត។**



ខណៈដែលកាលពីមុន រោងចក្ររបស់អ្នកអាចពឹងផ្អែកខ្លាំងលើការផលិតសម្លៀកបំពាក់សម្រាប់អ្នកបញ្ជាទិញតែមួយ ឬអ្នកបញ្ជាទិញមួយចំនួនតូច វិបត្តិដូចជាការរាតត្បាតនៃមេរោគកូវីដ-១៩ អាចបង្ខំអ្នកឱ្យស្វែងរកមធ្យោបាយរកប្រាក់ចំណូលថ្មីៗបន្ថែមទៀត។ ការស្វែងរកប្រភពចំណូលផ្សេងទៀត ឬ *ការធ្វើពិពិធកម្ម* ប្រភពចំណូលរបស់អ្នកអាចជួយរោងចក្ររបស់អ្នកឱ្យ៖

- ដោះស្រាយបញ្ហាលំហូរសាច់ប្រាក់បច្ចុប្បន្ន
- កាន់តែមានភាពធន់នឹងវិបត្តិនាពេលអនាគត
- ភ្ជាប់ទំនាក់ទំនងជាមួយអ្នកទិញ និងទីផ្សារថ្មីៗ
- សូមចំណាយពេលដើម្បីស្វែងរកឱកាសថ្មីៗសម្រាប់អាជីវកម្មរបស់អ្នក។

## 2. ការស្វែងរកប្រភពចំណូលផ្សេងទៀត

នៅក្នុងគោលការណ៍ណែនាំនេះ អ្នកនឹងសិក្សាពីប្រភពចំណូល ៣ ប្រភេទដែលអាចមានសម្រាប់រោងចក្ររបស់អ្នក។ ប្រភពទាំងនេះរួមមាន៖

- **ការផ្តល់ជំនួយបណ្តោះអាសន្ន ឬការគាំទ្រផ្នែកហិរញ្ញវត្ថុ៖** រដ្ឋាភិបាល ស្ថាប័នហិរញ្ញវត្ថុអន្តរ

ជាតិ រដ្ឋាភិបាលប្រទេសម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀតក្នុងឧស្សាហកម្មកំពុងផ្តល់មូលនិធិដើម្បីបន្ធូរបន្ថយសម្ពាធហិរញ្ញវត្ថុដល់រោងចក្រកាត់ដេរក្នុងអំឡុង ពេលនៃជំងឺកូវីដ-១៩។ អាស្រ័យថាតើរោងចក្ររបស់អ្នកមានមូលដ្ឋាននៅប្រទេសណា កញ្ចប់ថវិកាសម្រាប់អ្នកអាចមានលក្ខណៈផ្សេងៗគ្នា។ គេហទំព័ររដ្ឋាភិបាល សមាគមរោងចក្រកាត់ដេររបស់អ្នក និងធនាគារគឺជាប្រភពព័ត៌មានដ៏ល្អ។ ត្រូវប្រាកដថាអ្នកបានត្រៀមខ្លួនជាស្រេចដើម្បីដាក់ពាក្យស្នើសុំកញ្ចប់ជំនួយហិរញ្ញវត្ថុ ដោយរក្សាកំណត់ត្រាគណនី និងឯកសារផ្សេងទៀតដើម្បីបំពេញតាមតម្រូវការរបស់ស្ថាប័នដែលផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុទាំងនោះ។

- **ទីផ្សារផលិតផលរយៈពេលខ្លី៖** ឧបករណ៍ការពារផ្ទាល់ខ្លួន (PPE) នៅតែមានតម្រូវការខ្ពស់ពីអ្នកទិញជាច្រើននៅជុំវិញពិភពលោក។ ទោះបីនេះជាតម្រូវការបណ្តោះអាសន្នក៏ដោយ អ្នកអាចពិចារណាផលិតម៉ាស់ការពារមុខ ឬសំលៀកបំពាក់បុគ្គលិកសុខាភិបាល និងឧបករណ៍ការពារផ្ទាល់ខ្លួនផ្សេងទៀត ដើម្បីបន្តដំណើរការផលិតកម្មរបស់អ្នក។ ដើម្បីស្វែងយល់ព័ត៌មានបន្ថែមអំពីអ្នកបញ្ជាទិញ អ្នកអាចជជែកជាមួយសមាគមរោចក្រកាត់ដេររបស់អ្នក។ ក៏មានស្ថាប័នផ្សេងទៀតដែលបានព្យាយាមសម្របសម្រួលលើការផលិត (សូមអានព័ត៌មានបន្ថែមនៅក្នុងបញ្ជីរោងចក្រ) ។
- **ការធ្វើពិពិធកម្មរយៈពេលវែង៖**

  ការពឹងផ្អែកលើប្រភពចំណូលតែមួយនឹងធ្វើឱ្យរោងចក្ររបស់អ្នកប្រឈមនឹងហានិភ័យជាច្រើន។

  រោងចក្រគួរតែប្រើយុទ្ធសាស្រ្តដែលធានានូវការផ្គត់ផ្គង់ប្រាក់ចំណូលកាន់តែមានស្ថេរភាពដោយមានប្រភពចំណូលផ្សេងៗគ្នា។ មានយុទ្ធសាស្ត្របីប្រភេទ៖

  - *ការធ្វើពិពិធកម្មអ្នកបញ្ជាទិញ៖*

    អ្នកអាចពិចារណាលក់ទៅកាន់អ្នកបញ្ជាទិញកាន់តែច្រើន និង/ឬអ្នកបញ្ជាទិញថ្មីៗនាពេលខាងមុខ។ វាអាចមានទាំងវិជ្ជមាន និងអវិជ្ជមានសម្រាប់រោងចក្ររបស់អ្នក។ វាធ្វើឱ្យរោងចក្ររបស់អ្នកពឹងផ្អែកតិចតួចជាងមុនលើអ្នកទិញបច្ចុប្បន្នរបស់អ្នក។ ប៉ុន្តែ អ្នកក៏អាចទទួលបានអត្ថប្រយោជន៍កាន់តែពិសេសជាងមុនពីការធ្វើការជាមួយអតិថិជនបច្ចុប្បន្នរបស់អ្នក ដើម្បីទទួលបានពីការសហការកាន់តែជិតស្និទ្ធ និងការគាំទ្រសក្តានុពល។ ទោះយ៉ាងណាក៏ដោយ វាមិនល្អទេក្នុងការធ្វើការជាមួយអ្នកទិញតែមួយនោះ ព្រោះអ្នកមានហានិភ័យនៃការបាត់បង់អាជីវកម្ម ប្រសិនបើមានវិបត្តិស្រដៀងគ្នានេះកើតឡើងនាពេលអនាគត។
  - *ការធ្វើពិពិធកម្មផលិតផល៖* តើរោងចក្ររបស់អ្នកបានត្រៀមខ្លួនហើយឬនៅ ក្នុងការផលិតទំនិញដែលផ្តល់តម្លៃបន្ថែមដើម្បីធានាបាននូវប្រាក់ចំណេញខ្ពស់? សូម

ពិចារណាថាតើមានផលិតផលស្រដៀងនឹងផលិតផលដែលអ្នកកំពុងផលិត ហើយដែលអ្នកអាចចាប់ផ្ដើមផលិត ដើម្បីបង្កើនទំហំប្រតិបត្តិការរោងចក្ររបស់អ្នក និងផ្គត់ផ្គង់ដល់ទីផ្សារផ្សេងទៀតដែរឬទេ។ ឧទាហរណ៍៖ ប្រសិនបើបច្ចុប្បន្នអ្នកផលិតសំលៀកបំពាក់ត្បាញ ពេលនេះសូមពិចារណាថាតើអ្នកអាចចាប់ផ្ដើមសំលៀកបំពាក់ប៉ាក់ថែមទៀតបានដែរឬទេ។

- *ការធ្វើពិពិធកម្មសកម្មភាពរកប្រាក់ចំណូល៖*
  រោងចក្ររបស់អ្នកអាចរកលុយបានដោយការធ្វើសកម្មភាពដែលមិនទាក់ទងផ្ទាល់ទៅនឹងការផលិតសម្លៀកបំពាក់សម្រាប់ការបញ្ជាទិញផ្ទាល់របស់អ្នក។ ឧទាហរណ៍៖ អ្នកអាចចាប់ផ្ដើមដោយវិនិយោគលើផ្នែកប៉ាក់ ផ្នែកបោះពុម្ព ឬផ្នែកបោកគក់ អាចធ្វើទាំងនៅក្នុងបរិវេណរបស់អ្នកដោយប្រើទីកន្លែងរបស់អ្នកឱ្យកាន់តែមានប្រសិទ្ធិភាព ឬដោយជួលកន្លែងដែលអាចធ្វើវាបាន។ ម៉្យាងទៀត អ្នកក៏អាចជួលផ្នែកខ្លះនៃគ្រឿងបរិក្ខារ ឬគ្រឿងម៉ាស៊ីនរបស់អ្នក ដើម្បីទទួលបានប្រាក់ចំណូលពីការជួលរៀងរាល់ខែ។

## ៣- ការត្រៀមខ្លួនសម្រាប់ធ្វើសកម្មភាព

ក្រោយពីអ្នកបានពិចារណាលើប្រភពចំណូលដែលអាចរកបានសម្រាប់រោងចក្ររបស់អ្នកហើយ ផ្នែកបន្ទាប់នឹងផ្ដល់នូវជំហានជាក់លាក់មួយចំនួនស្ដីពីវិធីស្វែងរកប្រភពចំណូលទាំងនេះ និងកំណត់ប្រភពដែលសមស្របបំផុតសម្រាប់រោងចក្ររបស់អ្នកក្នុងរយៈពេលខ្លី និងរយៈពេលវែង។



# វិធី ៦ យ៉ាងសម្រាប់រោងចក្ររកប្រភពចំណូលថ្មីៗ

## ០១ កំណត់កញ្ចប់ជំនួយសង្គ្រោះបន្ទាន់ដែលអាចរកបាន

ដើម្បីដោះស្រាយសម្ពាធហិរញ្ញវត្ថុក្នុងរយៈពេលខ្លី។

## ០២ ស្វែងរកទីផ្សារផលិតផលរយៈពេលខ្លីដែលអាចរកបាន

សូមពិចារណាផលិតឧបករណ៍ការពារផ្ទាល់ខ្លួន
ដែលបច្ចុប្បន្នកំពុងមានតម្រូវការខ្ពស់។

## ០៣ ត្រៀមផលិតសម្រាប់ការបញ្ជាទិញក្នុងបរិមាណតិចៗ ឱ្យបានឆាប់រហ័ស!

អ្នកលក់រាយនឹងត្រូវការផលិតផលថ្មីភ្លាមៗនៅពេលមានការបើកទីផ្សារឡើងវិញ។

## ០៤ សហការជាមួយអ្នកដទៃ

ចូលរួមក្នុងការពិភាក្សានានាជាមួយអ្នកពាក់ព័ន្ធក្នុងឧស្សាហកម្ម។

## ០៥ លក់អ្វីដែលអ្នកមានស្រាប់

សំរាមរបស់មនុស្សម្នាក់អាចជាទ្រព្យរបស់មនុស្សម្នាក់ទៀត។

## ០៦ ស្វែងរកអ្នកទិញថ្មីៗ

ស្វែងរកបណ្តាញផ្សេងៗដើម្បីកំណត់អត្តសញ្ញាណអ្នកទិញថ្មីៗ។

# ចាប់ផ្តើមអនុវត្តវិធានការ៖ បញ្ជីត្រួតពិនិត្យរោងចក្រ

## 1. កំណត់កញ្ចប់ជំនួយសង្គ្រោះបន្ទាន់ដែលអាចរកបាន

បច្ចុប្បន្ន រដ្ឋាភិបាលជាច្រើនគាំទ្រដល់អាជីវកម្មដែលកំពុងជួបបញ្ហាហិរញ្ញវត្ថុដោយសារជំងឺ កូវីដ-១៩។ ការគាំទ្រអាចក្នុងទម្រង់ជាប្រាក់កម្ចីអាជីវកម្មអនុគ្រោះ ឥណទាន។ ល។ ទោះជាវាមិនមែនជាដំណោះស្រាយរយៈពេលវែងក៏ដោយ កញ្ចប់ជំនួយទាំងនេះអាចជួយអ្នកដោះស្រាយស្ថានការណ៍ហិរញ្ញវត្ថុដែលរោងចក្ររបស់អ្នកកំពុងជួបប្រទះ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| សូមជជែកជាមួយសមាគមរោងចក្រកាត់ដេររបស់អ្នកអំពីកញ្ចប់ជំនួយហិរញ្ញវត្ថុដែលមានសម្រាប់រោងចក្រកាត់ដេរ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| ស្វែងរកព័ត៌មានតាមអ៊ីនធឺណិត។ ព័ត៌មានអាចមាននៅលើគេហទំព័ររដ្ឋាភិបាល នៅតាមកាសែតក្នុងស្រុក ឬវេទិកានានាក្នុងឧស្សាហកម្មនេះ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| សូមត្រៀមខ្លួនដើម្បីដាក់ពាក្យស្នើសុំការគាំទ្រ។ រៀបចំឯកសាររបស់អ្នកតាមលំដាប់លំដោយ រួមទាំងការកំណត់ត្រាគណនីរបស់អ្នក។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |

## 2. ស្វែងរកទីផ្សារផលិតផលរយៈពេលខ្លីដែលអាចមាន

ក្នុងពេលបច្ចុប្បន្ននេះ អាចមានឱកាសតិចតួចក្នុងការផលិតសម្លៀកបំពាក់ធម្មតាសម្រាប់រោងចក្ររបស់អ្នក។ ដោយសារជំងឺរាតត្បាតនេះ ផលិតផលសំលៀកបំពាក់សម្រាប់ការពារខ្លួន ដូចជាម៉ាស់ ឬរបគ្រូពេទ្យបច្ចុប្បន្នមានតម្រូវការខ្ពស់។ ការផ្លាស់ប្តូរផលិតកម្មទៅការផលិតឧបករណ៍ការពារផ្ទាល់ខ្លួនអាចផ្តល់ឱ្យអ្នកនូវឱកាសដើម្បីទទួលបានប្រាក់ចំណូលក្នុងអំឡុងពេលនៃជំងឺរាតត្បាតនេះ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| សូមស្វែងរកអ្នកទិញឧបករណ៍ការពារផ្ទាល់ខ្លួននៅលើតាមអ៊ីនធឺណិត ដូចជាសហព័ន្ធសម្លៀកបំពាក់ និងវាយនភណ្ឌអ៊ឺរ៉ុប (EURATEX) ដែលបច្ចុប្បន្នកំពុងព្យាយាមសម្របសម្រួលការលក់ឧបករណ៍ការពារផ្ទាល់ខ្លួន។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| សហការជាមួយសមាគមរោងចក្រកាត់ដេររបស់អ្នកដើម្បីស្វែងរកឱកាសផលិតឧបករណ៍ការពារផ្ទាល់ខ្លួន សម្រាប់ទីផ្សារក្នុងស្រុក ឬសម្រាប់ទីផ្សារនាំចេញ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| សហការជាមួយរោងចក្រផ្សេងទៀតដើម្បីអាចទទួលបានការបញ្ជាទិញធំៗជាងមុន ឬផលិតសម្រាប់រោងចក្រធំៗដែលមានអាជ្ញាប័ណ្ណនាំចេញ។ | ✓✓ | »» រយៈពេលខ្លី | ☐ |

## 3. ត្រៀមផលិតសម្រាប់ការបញ្ជាទិញក្នុងបរិមាណតិចៗ - ឱ្យបានឆាប់រហ័ស!

ការរាតត្បាតជាសាកលនៃជំងឺកូវីដ-១៩បានបង្កឱ្យខូចដល់រដូវកាលទិញសម្រាប់អ្នកទិញនៅឆ្នាំនេះ។ ក្នុងអំឡុងពេលនៃការរីករាលដាល ហើយនៅពេលដែលវាចប់ ហាងលក់ទំនិញទាំងនេះនឹងត្រូវការទំនិញថ្មីយ៉ាងឆាប់រហ័ស ព្រោះពួកគេមានតែទំនិញពីរដូវកាលមុនប៉ុណ្ណោះ។

| សកម្មភាព | ភាពងាយស្រួលនៃ | ពេលវេលា | ធីក |
|---|---|---|---|

| | ការអនុវត្ត | | ✓ |
|---|---|---|---|
| ជជែកជាមួយអ្នកទិញរបស់អ្នកអំពីការផលិតដើម្បីផ្គត់ផ្គង់ដល់ការបញ្ជាទិញតូចៗ។ សហកាគ្នាស្វែងយល់ពីរយៈពេល ទំហំនៃការបញ្ជាទិញ និងរយៈពេលផលិតចាំបាច់។ វានឹងជួយអ្នកក្នុងការរៀបចំរោងចក្ររបស់អ្នក ប្រសិនបើអ្នកទទួលបានការបញ្ជាទិញ។ | ✓✓ | ››› រយៈពេលខ្លី | ☐ |
| ព្យាយាមប្រើក្រណាត់ក្នុងស្តុកឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ ត្រូវប្រាកដថាអ្នកមានសន្និធិនៃវាយនភ័ណ្ឌ និងសម្ភារៈផ្សេងទៀតទាំងអស់ ដើម្បីឱ្យអ្នកមានព័ត៌មានគ្រប់គ្រាន់នៅពេលអ្នកទទួលបានការបញ្ជាទិញថ្មីៗ។ | ✓✓✓ | ››› ››› រយៈពេលមធ្យម | ☐ |
| រក្សាទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់របស់អ្នកដើម្បីឱ្យអ្នកមានព័ត៌មានអំពីសន្និធិដែលអាចរកបាន។ | ✓✓✓ | ››› ››› រយៈពេលមធ្យម | ☐ |
| ត្រូវប្រាកដថាអ្នករៀបចំខ្លួនជាមុនដើម្បីអាចផ្តល់លក្ខខណ្ឌការងារគ្រប់គ្រាន់សម្រាប់កម្មកររបស់អ្នក។ វាមិនគួរបង្កឱ្យមានការងារលើសម៉ោង ឬកង្វះការពិចារណាលើវិធានការសុខភាព និងសុវត្ថិភាពហួសហេតុឡើយ។ | ✓✓✓ | ››› ››› រយៈពេលមធ្យម | ☐ |

## 4. សហការជាមួយអ្នកដទៃ

ព្យាយាមចូលរួមក្នុងកិច្ចពិភាក្សានានាជាមួយក្រុមហ៊ុនផលិត ហាងលក់ទំនិញ សមាគមនិយោជក និងសហជីពផ្សេងៗទៀត។ វាអាចជួយដាក់សម្ពាធលើអ្នកទិញឱ្យបង់ប្រាក់សម្រាប់ការបញ្ជាទិញដែលបានផលិតហើយ ឬកំពុងផលិត។ នេះក៏ជាពេលវេលាដ៏កម្រមួយសម្រាប់ឧស្សាហកម្មឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ន និងធ្វើការកែលម្អវាឱ្យកាន់តែប្រសើរឡើង។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| ចូលរួមជាមួយសមាគមរោងចក្រកាត់ដេរ។ សមាគមតំណាងឱ្យវិស័យនេះ ហើយអាចធ្វើការចរចាជំនួសអ្នក និងរោងចក្រផ្សេងទៀត។ ធ្វើឱ្យគេដឹងឮសម្លេងរបស់អ្នក និងធ្វើឱ្យសមាគមកាន់តែរឹងមាំដោយចូលរួមជាមួយពួកគេ។ | ✓✓✓ | ››› រយៈពេលខ្លី | ☐ |
| ទាក់ទងទៅរកអ្នកទិញរបស់អ្នក។ ពន្យល់ពីស្ថានភាពរបស់អ្នក ហើយសួរថាតើមានវិធីសហការគ្នាដើម្បីអាចដោះស្រាយវិបត្តិនេះជាមួយគ្នាបានទេ? | ✓✓✓ | ››› រយៈពេលខ្លី | ☐ |
| ជជែកជាមួយរោងចក្រផ្សេងទៀត។ ប្រសិនបើពួកគេទទួលបានការបញ្ជាទិញធំៗ ប្រហែលជាពួកគេត្រូវផ្តល់ការងារបន្តសម្រាប់ផ្នែកខ្លះនៃការបញ្ជាទិញនោះ ប្រសិនបើតម្រូវការរយៈពេលផលិតខ្លី (ដែលវាទំនងជាដូច្នោះ) ។ | ✓✓✓ | ››› រយៈពេលខ្លី | ☐ |

## 5. លក់អ្វីដែលអ្នកមានស្រាប់

អ្នកអាចមានរបស់របរផ្សេងៗនៅក្នុងរោងចក្ររបស់អ្នក ដែលអ្នកអាចលក់ដើម្បីទទួលបានសាច់ប្រាក់បន្ថែមក្នុងរយៈពេលខ្លី។ សូមចងចាំថាសំរាមរបស់មនុស្សម្នាក់អាចជាទ្រព្យសម្បត្តិរបស់មនុស្សម្នាក់ទៀត។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|

| | | | |
|---|---|---|---|
| ពិនិត្យការស្តុករបស់អ្នក។ ក្នុងពេលនេះ រោងចក្រផ្សេងទៀតប្រហែលជាចង់ទិញវាយនភ័ណ្ឌខ្លះរបស់អ្នក ក្នុងករណីដែលអ្នកផ្គត់ផ្គង់របស់ពួកគេមិនអាចផ្គត់ផ្គង់ទាន់ពេលវេលា ឬខ្វះបរិមាណក្រណាត់ដែលត្រូវការ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| លក់ម៉ាស៊ីនខ្លះរបស់អ្នក។ នៅក្នុងរោងចក្រជាញឹកញាប់មានម៉ាស៊ីនដែលគេលែងប្រើ។ សូមពិនិត្យមើលថាតើមានទីផ្សារជជុះសម្រាប់លក់ម៉ាស៊ីនដែលអ្នកមិនប្រើឬទេ។ រោងចក្រផ្សេងទៀតអាចចាប់អារម្មណ៍នឹងគ្រឿងបន្លាស់ ឬផ្លាស់ប្តូរម៉ាស៊ីនខូចរបស់ពួកគេ។ | ✓✓✓ | »» រយៈពេលខ្លី | ☐ |
| តើអ្នកមានទីកន្លែងទំនេរទេ? សូមពិចារណាជួលវាក្នុងរយៈពេលខ្លី ឬវែង ដើម្បីទទួលបានប្រាក់ចំណូលបន្ថែមជារៀងរាល់ខែ។ | ✓✓ | »» រយៈពេលខ្លី | ☐ |

## 6. ស្វែងរកអ្នកទិញថ្មីៗ

ប្រសិនបើអតិថិជនដែលអ្នកមានស្រាប់មិនចង់ទិញពីអ្នកនៅពេលនេះ អ្នកគួរតែពិចារណារកអតិថិជនផ្សេងទៀតដែលចង់ឱ្យអ្នកផលិតសម្លៀកបំពាក់សម្រាប់ពួកគេ។ មានបណ្តាញផ្សេងៗដែលអាចជួយអ្នកក្នុងការធ្វើបែបនេះ។

| សកម្មភាព | ភាពងាយស្រួលនៃការអនុវត្ត | ពេលវេលា | ធីក ✓ |
|---|---|---|---|
| រៀបចំអាជីវកម្មរបស់អ្នកនៅលើអ៊ីនធឺណិត។ ព្យាយាមស្វែងរកអតិថិជនតាមអ៊ីនធឺណិតនៅតាមវេទិកាស្វែងរកអ្នកផ្គត់ផ្គង់ផ្សេងៗ។ **គន្លឹះមានប្រយោជន៍៖** សូមមើលការណែនាំស្តីពី "ការបង្កើតវត្តមានវត្តមានអាជីវកម្មនៅលើអ៊ីនធឺណិត" ដើម្បីជួយអ្នកឱ្យចាប់ផ្តើម។ | ✓✓ | »» រយៈពេលមធ្យម | ☐ |
| ជជែកជាមួយបណ្តាញរបស់អ្នក។ ខណៈដែលបច្ចុប្បន្ន រោងចក្រជាច្រើនកំពុងស្វែងរកឱកាស អ្នកប្រហែលជាអាចទទួលបានគន្លឹះ និងគំនិតពីអ្នកដទៃអំពីវិធីស្វែងរកអតិថិជនថ្មីៗ។ | ✓✓ | »» រយៈពេលមធ្យម | ☐ |
| ប្រសិនបើមានការលំបាកក្នុងការលក់ទៅឱ្យរោងចក្រ ឬអ្នកទិញដែលផ្តោតលើការនាំចេញ នៅពេលនេះសូមផ្តោតលើទីផ្សារក្នុងស្រុក ឬយ៉ាងហោចណាស់ក្នុងតំបន់។ វាអាចងាយស្រួលជាង ក្នុងការស្វែងរកអ្នកទិញដែលមានបំណងបញ្ជាទិញពីអ្នក ព្រោះខ្សែចង្វាក់ផ្គត់ផ្គង់មិនសូវមានការរំខាន។ | ✓✓ | »» រយៈពេលមធ្យម | ☐ |

Sweden Sverige

គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបចំឡើងដោយនាយកដ្ឋានសហគ្រាសរបស់អង្គការ ILO សម្រាប់ **គម្រោងការងារសមរម្យនៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់វិស័យកាត់ដេរនៅអាស៊ី** ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាលស៊ុយអែត។

សម្រាប់ឯកសារ ឬធនធានផ្សេងៗទៀតដើម្បីជួយអ្នកដោះស្រាយស្ថានភាពក្នុងអំឡុងពេលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ សូមចូលទៅកាន់៖

▶ ilo.org/covid19

**ក្រុមការងារគាំទ្របច្ចេកទេសគម្រោងការងារសមរម្យ**
**សម្រាប់តំបន់អាស៊ីបូព៌ា និងអាស៊ីអាគ្នេយ៍ និងប៉ាស៊ីហ្វិក**
អគារអង្គការសហប្រជាជាតិ ជាន់ទី ១០ ផ្លូវ Rajdamnern Nok
ទីក្រុងបាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទលេខ៖ ៦៦២ ២៨៨ ១២៣៤ ទូរសារ៖ ៦៦២ ២៨៨ ៣០៥៨
អ៊ីម៉ែល៖ BANGKOK@ilo.org

DECENT WORK
A better world starts here.